# ការរៀបចំផែនការគម្រោងគ្រាប់ពូជ និងការធ្វើរបាយការណ៍
# Planning Seed Projects

## ការរៀបចំផែនការគម្រោងគ្រាប់ពូជ

### សេចក្តីសង្ខេប:

ការរៀបចំផែនការស្របតាមព្រះគម្ពីរ។ ការរៀបចំផែនការគម្រោងគ្រាប់ពូជគឺជាគំរូដែលសាមញ្ញ សម្រាប់ស្គាល់អត្តសញ្ញាណ រៀបចំផែនការ និងសម្រេចគម្រោងនគរព្រះខ្នាតតូចនៅក្នុងសហគមន៍មូលដ្ឋាន។

### គំនិតចម្បង:

១. ការរៀបចំផែនការឆ្លុះបញ្ចាំងឱ្យឃើញព្រះអាទិកររបស់យើង។ ព្រះអង្គគឺជាព្រះដែលមានសណ្តាប់ធ្នាប់។

២. គម្រោងគ្រាប់ពូជឆ្លុះបញ្ចាំងឱ្យឃើញព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះផ្នែកជាក់លាក់មួយដែលមានភាពបាក់បែកនៅក្នុងសហគមន៍របស់យើង។ ការរៀបចំផែនការគម្រោងគ្រាប់ពូជស្គាល់ជំហានតូចមួយដែលយើងនឹងធ្វើឆ្ពោះទៅរកព្រះហឫទ័យយកចិត្តទុកដាក់នោះ។

៣. ការរៀបចំផែនការល្អជួយយើងឱ្យស្គាល់លំដាប់លំដោយនៃជំហាន និងការទទួលខុសត្រូវដែលត្រូវការ ដើម្បីសម្រេចគោលបំណងចុងក្រោយ។

៤. ផែនការត្រូវតែពិចារណាលក្ខណៈទាំងអស់របស់គម្រោងគ្រាប់ពូជ។

### លទ្ធផល:

១. ឥឡូវនេះ:

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. ស្គាល់ផ្នែកមួយដែលព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់នៅក្នុងសហគមន៍របស់ពួកគេដែលនៅក្រៅពួកជំនុំ និងរៀបចំផែនការគម្រោងគ្រាប់ពូជមួយនៅក្នុងអំឡុងពេលរៀនមេរៀន។

២. ទៅមុខទៀត

ក. ស្គាល់សេចក្តីត្រូវការឱ្យមានគម្រោងគ្រាប់ពូជដែលមានបន្ត មានតុល្យភាព និងមានការផ្តោតអារម្មណ៍នៅក្នុងសហគមន៍របស់ពួកគេ និងប្តេជ្ញាចិត្តរៀបចំផែនការគម្រោងគ្រាប់ពូជថែមទៀត ជារបៀបផ្សាយដំណឹងល្អគ្រប់ជ្រុងជ្រោយ ។

ខ. ធ្វើការជាអ្នកដឹកនាំដើម្បីបញ្ចប់គម្រោងគ្រាប់ពូជមួយជាមួយមនុស្សមួយក្រុមនៅក្នុងពួកជំនុំមូលដ្ឋានរបស់ពួកគេនៅក្នុងខែក្រោយ ។

# ការធ្វើរបាយការណ៍គម្រោងគ្រាប់ពូជ

## សេចក្តីសង្ខេប:

ការធ្វើរបាយការណ៍គម្រោងគ្រាប់ពូជជួយឱ្យពួកជំនុំមូលដ្ឋានអាចរៀនចេញពីគម្រោងគ្រាប់ពូជរបស់ពួកគេដែលបានបញ្ចប់រួចហើយ រៀបចំផែនការសម្រាប់គម្រោងនៅពេលអនាគតដែលបង្ហាញចេញសេចក្តីស្រលាញ់ និងព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ចំពោះសេចក្តីត្រូវការនៅក្នុងសហគមន៍ និងរីកចម្រើនឡើងនៅក្នុងរបៀបរស់នៅដែលមានការបម្រើគ្រប់ជ្រុងជ្រោយ ។

## គំនិតចម្បង:

១. ការធ្វើរបាយការណ៍ និងការឆ្លុះបញ្ចាំងអំពីគម្រោងគ្រាប់ពូជដែលបានបញ្ចប់រួចហើយ ជួយយើងរៀនអំពីរបៀបថ្វាយព្រះកិត្តិយស និងថ្វាយសិរីល្អដល់ព្រះជាម្ចាស់កាន់តែប្រសើរជាងមុន និងជួយមនុស្សដទៃទៀតឱ្យមើលឃើញសេចក្តីស្រលាញ់ និងព្រះគុណរបស់ព្រះអង្គ ។

២. ការវាយតម្លៃគម្រោងគ្រាប់ពូជដែលបានបញ្ចប់រួចហើយរួមមានអ្វីដែលមានប្រយោជន៍ អ្វីដែលមានបញ្ហា និងអ្វីដែលអាចកែលម្អរឱ្យកាន់តែប្រសើរឡើងបាន ។

៣. ក្រោយពីធ្វើរបាយការណ៍ និងវាយតម្លៃរួចហើយ រៀបចំផែនការសម្រាប់លក្ខណៈ និងពេលវេលារបស់គម្រោងគ្រាប់ពូជនៅពេលអនាគត ដើម្បីឱ្យគម្រោងទាំងនោះបន្ត មានតុល្យភាព និងមានការផ្តោតអារម្មណ៍លើមនុស្សដដែលមួយរយៈពេល ។

## លទ្ធផល:

៣. ឥឡូវនេះ:

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ ។

ខ. និយាយជាមួយមនុស្សម្នាក់នៅសប្តាហ៍ក្រោយអំពីសារៈសំខាន់នៃការធ្វើគម្រោងគ្រាប់ពូជ ដែលបម្រើគោលបំណងពេញលេញរបស់ព្រះជាម្ចាស់ដល់មនុស្សដដែលមួយរយៈពេល ។

៤. ទៅមុខទៀត

ក. ទទួលស្គាល់សារៈសំខាន់របស់ការបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដែលមានលក្ខណៈបន្ត និងមានតុល្យភាព ព្រមទាំងប្តេជ្ញាចិត្តរៀបចំផែនការ សម្រេច និងវាយតម្លៃគម្រោងគ្រាប់ពូជទាំងអស់ដែលបានធ្វើនៅក្នុងសហគមន៍របស់ពួកគេ ។

ខ. ប្តេជ្ញាចិត្តជាអ្នកដឹកនាំដើម្បីបង្កើតពេលធ្វើរបាយការណ៍ ឆ្លុះបញ្ចាំង និងវាយតម្លៃគម្រោងគ្រាប់ពូជទីមួយរបស់ពួកគេនៅក្នុងរយៈពេលបីខែក្រោយ ។

# ការរៀបចំផែនការគម្រោងគ្រាប់ពូជ និងការធ្វើរបាយការណ៍

## គ្រោងមេរៀនសម្រាប់សិស្ស

### ១. សេចក្ដីផ្ដើម

### ២. ខគម្ពីរគន្លឹះ៖ លូកា ១៤:២៨-៣០

ចូរសរសេរគំនិតចម្បងរបស់ខគម្ពីរនេះតាមពាក្យរបស់អ្នក។

### ៣. ការណែនាំអំពីការរៀបចំផែនការគម្រោងគ្រាប់ពូជ

ក. ផ្នែកចំណងជើង

១. បញ្ហា៖ ____________________

២. គោលបំណងរបស់ព្រះជាម្ចាស់៖ ____________________

៣. បទគម្ពីរ៖ ____________________

៤. ចំណងជើងគម្រោងគ្រាប់ពូជ៖ ____________________

៥. ឥទ្ធិពលចម្បង៖ ____________________

៦. ឥទ្ធិពលបន្ទាប់បន្សំ៖ ____________________

ខ.   ផ្នែកផែនការ (សូមមើលឯកសារនៅខាងចុងគ្រោងមេរៀន)

| **ដំណាក់កាលគម្រោង** | **អ្នកប្រឹក្សា** | **ធនធានត្រូវការ** | **អ្នកតំណាង** | **ថ្ងៃចប់** |
|---|---|---|---|---|
| ១. អធិស្ឋាន និងការសម្រេចចិត្ត | ព្រះជាម្ចាស់ | ពេលវេលា និងការសញ្ជឹងគិត | អ្នកដឹកនាំពួកជំនុំ | ថ្ងៃទី ១ |
| ១២. សង់បង្គន់ | ក្រុមជំនុំ /សហគមន៏ | ចុងសប្តាហ៏ដែលទំនេរ | គណៈកម្មការគម្រោង | ថ្ងៃទី ១៦-១៧ |

## ៤.   ការពិនិត្យមើលផែនការ

ក.   ផ្នែកទទួលរងឥទ្ធិពល

១. ប្រាជ្ញា

២. ខាងសាច់ឈាម

៣. ខាងវិញ្ញាណ

៤. ខាងសង្គម

ខ.   លក្ខណៈ

១.   បណ្តាលចិត្តដោយសារគោលបំណងរបស់ព្រះជាម្ចាស់

២.   គ្រប់បាំងនៅក្នុងការអធិស្ឋាន

៣.   សាមញ្ញ និងមានរយៈពេលខ្លី

៤.   រៀបចំផែនការឱ្យបានល្អ

| **១០ លក្ខណៈ** | |
|---|---|
| ១. បណ្តាលចិត្តដោយសារគោលបំណងរបស់ព្រះជាម្ចាស់<br>២. គ្របបាំងនៅក្នុងការអធិស្ឋាន<br>៣. សាមញ្ញ និងមានរយៈពេលខ្លី<br>៤. រៀបចំផែនការឱ្យបានល្អ<br>៥. ធនធាននៅក្នុងមូលដ្ឋាន | ៦. មិនបោកបញ្ឆោត<br>៧. នៅខាងក្រៅពួកជំនុំ<br>៨. អ្នកដែលទទួលបានផលប្រយោជន៏ចូលរួម<br>៩. មានគោលបំណងគ្រប់ជ្រុងជ្រោយ<br>១០. ព្រះជាម្ចាស់ត្រូវបានលើកតម្កើង |

៥. ធនធាននៅក្នុងមូលដ្ឋាន

៦. មិនបោកបញ្ឆោត

៧. ធ្វើសម្រាប់អ្នកនៅខាងក្រៅពួកជំនុំ

៨. អ្នកដែលទទួលបានផលប្រយោជន៍ចូលរួម

៩. រៀបចំផែនការដោយមានគោលបំណងឱ្យមានឥទ្ធិពលគ្រប់ជ្រុងជ្រោយ

១០. ព្រះជាម្ចាស់ត្រូវបានលើកតម្កើង

## ៤. កែប្រែ និងធ្វើគម្រោងគ្រាប់ពូជ (កុំភ្លេចថតរូប)

## ៥. ការវាយតម្លៃគម្រោង

ក. ការពណ៌នា

ខ. អ្វីដែលបានសម្រេច

គ. បញ្ហា

ឃ. មេរៀនដែលរៀនបាន

## ៦. ការធ្វើរបាយការណ៍គម្រោងគ្រាប់ពូជ

ក. អបអរជាមួយពួកជំនុំរបស់លោកអ្នក

ខ. ធ្វើរបាយការណ៍ផ្ញើទៅ Harvest ។

■ សូមប្រាប់យើងអំពីគម្រោងគ្រាប់ពូជដែលលោកអ្នកបានបញ្ចប់ ។ សូមមើលគេហទំព័ររបស់យើងសម្រាប់ព័ត៌មានលម្អិតៈ www.harvestfoundation.org ។

■ ថតរូប

## ៧. ការរៀបចំផែនការរយៈពេលវែង

ក. ពិនិត្យមើលឡើងវិញគោលការណ៍ទាំងបីសម្រាប់ប្រសិទ្ធភាពរយៈពេលវែង

១. មានតុល្យភាព

២. មានការផ្ដោតអារម្មណ៍

៣. បន្ត

ខ. រៀបចំផែនការសម្រាប់គម្រោងគ្រាប់ពូជបន្ទាប់

១. អធិស្ឋាន

២. ជ្រើសរើសបញ្ហា

៣. ជ្រើសរើស និងរៀបចំផែនការសម្រាប់គម្រោងបន្ទាប់

៤. ប្រៀបធៀបជាមួយលក្ខណៈរបស់គម្រោងគ្រាប់ពូជ

៥. កែសម្រួល និងអនុវត្តផែនការ

៦. វាយតម្លៃ និងធ្វើរបាយការណ៍

៧. រៀបចំផែនការសម្រាប់គម្រោងគ្រាប់ពូជថ្មី និងបន្តទៀត

## ៨. ការរីកចម្រើនច្រើនឡើងនៃគម្រោងគ្រាប់ពូជរបស់លោកអ្នក

ក. ចែកចាយ / បង្រៀនគោលការណ៍របស់គម្រោងគ្រាប់ពូជ និងវិធីសាស្ត្រដល់ក្រុមតូចមួយផ្សេងទៀត និង / ឬក្រុមជំនុំមូលដ្ឋានមួយផ្សេងទៀត ។

ខ. ចែកចាយរបាយការណ៍គម្រោងគ្រាប់ពូជរបស់លោកអ្នកជាមួយអ្នកដទៃ - ដោយមានរូបថត!!

១. អង្គការ Harvest

២. អ្នកដឹកនាំសហគមន៍

៣. ពួកជំនុំមូលដ្ឋានដទៃទៀត

# គំរូផែនការ #១

## ចំណាងជើង

**១. បញ្ហា:** បង្គន់សាធារណៈ ។

**២. គោលបំណងរបស់ព្រះជាម្ចាស់:** រស់នៅក្នុងបរិដ្ឋានស្អាត ។ **៣. បទគម្ពីរ:** លេវីវិន័យ ១១:៣៦ ។

**៤. ចំណងជើងគម្រោងគ្រាប់ពូជ:** ការសាងសង់បង្គន់សាធារណៈ ។

**៥. ឥទ្ធិពលចម្បង:** ខាងសាច់ឈាម ។ **៦. ឥទ្ធិពលបន្ទាប់បន្សំ:** ខាងសង្គម + ខាងវិញ្ញាណ

## ផែនការ

| *ជំហានក្នុងគម្រោង* | **អ្នកត្រូវប្រឹក្សាជាមួយ** | **ធនធានដែលត្រូវការ** | **អ្នកទទួលខុសត្រូវ** | **ថ្ងៃបញ្ចប់** |
|---|---|---|---|---|
| ១.ការអធិស្ឋាន និង ការសម្រេចចិត្ត | ព្រះជាម្ចាស់ | ពេលវេលា ការតស៊ូ បញ្ចាំង | អ្នកដឹកនាំក្រុមជំនុំ | ថ្ងៃទី ១ |
| ២. យោបល់អ្នកដឹកនាំសហគមន៍ | ចៅហ្វាយក្រុង និង/ ឬ សមាជិកសភា | ការណាត់ជួប | គណៈកម្មការគម្រោង | ថ្ងៃទី ២-៤ |
| ៣. បង្កើតកម្រងសំណួរ | គណៈកម្មការគម្រោង | គំនិត | គណៈកម្មការគម្រោង | ថ្ងៃទី ៥ |
| ៤. អធិស្ឋាន | ពួកជំនុំ | -------- | គណៈកម្មការគម្រោង | ថ្ងៃទី ៥ |
| ៥. ស្ទង់មតិអំពីផលប្រយោជន៍ | សហគមន៍ និងសមាជិកសភា | កម្រងសំណួរ | គណៈកម្មការគម្រោង | ថ្ងៃទី ៦ |
| ៦. បង្កើតម៉ូឌុ និង ផែនការសាងសង់ | វិស្វករសម្រាប់ប្លង់ សមាជិកសភាសម្រាប់ទីតាំងបង្គន់អនាម័យ | ជំនាញ<br>ការអនុញ្ញាត | អ្នកដឹកនាំគម្រោង និង វិស្វករ | ថ្ងៃទី ៨ |
| ៧. រៃអង្គាសមូលនិធិពីពួកជំនុំ និងសហគមន៍ | គ្រូគង្វាល និង សមាជិកសភា | ពេលវេលា | គណៈកម្មការគម្រោង | ថ្ងៃទី ៩-១០ |
| ៨. រកសំភារៈ | គណៈកម្មការគម្រោង | ស៊ីម៉ង់ ខ្សាច់ ថ្ម សំភារៈ | គណៈកម្មការគម្រោង | ថ្ងៃទី ១១-១២ |
| ៩. ប្រាប់កាលបរិច្ឆេទសាងសង់ | គណៈកម្មការគម្រោង | ប្លុកប៉ាដា | គណៈកម្មការគម្រោង | ថ្ងៃទី ១៥ |
| ១០. រៀបចំសម្រាប់អាហារ | ស្ត្រីនៅក្នុងពួកជំនុំ និង នៅក្នុងសហគមន៍ | មុខម្ហូប និងអ្នកស្ម័គ្រចិត្ត | គណៈកម្មការគម្រោង | ថ្ងៃទី ១៥ |
| ១១. ការអធិស្ឋាន | ពួកជំនុំ | ពេលវេលា | គ្រូគង្វាល | ថ្ងៃទី ១៥ |
| ១២. ការសាងសង់ | ពួកជំនុំ និងសហគមន៍ | ចុងសប្តាហ៍ដែលទំនេរ | គណៈកម្មការគម្រោង | ថ្ងៃទី ១៦-១៧ |
| ១៣. ការអបអរ និង ការថ្លែងអំណរគុណ | គ្រូគង្វាល និង ចៅហ្វាយក្រុង | --------- | គណៈកម្មការគម្រោង | ថ្ងៃទី ១៧ |
| ១៤. ការវាយតម្លៃ និង របាយការណ៍ | គណៈកម្មការគម្រោង | ពេលវេលា | គណៈកម្មការគម្រោង | ថ្ងៃទី ១៨ |

| | | | | |
|---|---|---|---|---|
| ១៥. ការអធិស្ឋាន និងការរៀបចំផែនការគម្រោងគ្រាប់ពូជថ្មី | គណៈកម្មការគម្រោង | ការឆ្លុះបញ្ចាំង | គណៈកម្មការគម្រោង | ថ្ងៃទី ២៥ |

## ចុងសន្លឹក

| ផ្នែកទទួលរងឥទ្ធិពលតាមផែនការ (សម្រាប់អ្នកទទួលបានគម្រោង ឬពួកជំនុំ) | លក្ខណៈគម្រោងគ្រាប់ពូជនៅក្នុងផែនការ |
|---|---|
| កត់ត្រាជំហានដែលផ្នែកទទួលរងឥទ្ធិពលខាងក្រោមត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញ:<br><br>• ___5__ ប្រាជ្ញា<br>• _____ខាងសាច់ឈាម<br>• _____ខាងវិញ្ញាណ<br>• _____ខាងសង្គម | កត់ត្រាជំហានដែលលក្ខណៈខាងក្រោមត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញ<br><br>• _______បណ្តាលចិត្តដោយសារគោលបំណងរបស់_____ព្រះជាម្ចាស់<br>• 1,4,11,15 គ្របបាំងនៅក្នុងការអធិស្ឋាន<br>• _______សាមញ្ញ និងមានរយៈពេលខ្លី<br>• _______រៀបចំផែនការឱ្យបានល្អ<br>• _______ធនធាននៅក្នុងមូលដ្ឋាន<br>• _______មិនបោកបញ្ឆោត<br>• _______នៅខាងក្រៅពួកជំនុំ<br>• _______អ្នកដែលទទួលបានផលប្រយោជន៍ចូលរួម<br>• _______មានគោលបំណងគ្រប់ជ្រុងជ្រោយ<br>• _______ព្រះជាម្ចាស់ត្រូវបានលើកតម្កើង |

# ការណែនាំអំពីការរៀបចំផែនការគម្រោងគ្រាប់ពូជ

## *ចំណងជើង*

១. បញ្ហា: ____________________

២. គោលបំណងរបស់ព្រះជាម្ចាស់: ____________________

៤. ចំណងជើងគម្រោងគ្រាប់ពូជ: ____________________

៥. ឥទ្ធិពលចម្បង: ____________________ ។ ៦. ឥទ្ធិពលបន្ទាប់បន្សំ: ____________________

## *ផែនការ*

| *ជំហានក្នុងគម្រោង* | *អ្នកត្រូវប្រឹក្សាជាមួយ* | *ធនធានដែលត្រូវការ* | *អ្នកទទួលខុសត្រូវ* | *ថ្ងៃបញ្ចប់* |
|---|---|---|---|---|
| ១. | | | | |
| ២. | | | | |
| ៣. | | | | |
| ៤. | | | | |
| ៥. | | | | |
| ៦. | | | | |
| ៧. | | | | |
| ៨. | | | | |
| ៩. | | | | |
| ១០. | | | | |
| ១១. | | | | |
| ១២. | | | | |
| ១៣. | | | | |
| ១៤. | | | | |
| ១៥. | | | | |

| *ជំហានក្នុងគម្រោង* | *អ្នកត្រូវប្រឹក្សាជាមួយ* | *ធនធានដែលត្រូវការ* | *អ្នកទទួលខុសត្រូវ* | *ថ្ងៃបញ្ចប់* |
|---|---|---|---|---|
| ១៦. | | | | |
| ១៧. | | | | |
| ១៨. | | | | |
| ១៩. | | | | |
| ២០. | | | | |
| ២១. | | | | |
| ២២. | | | | |
| ២៣. | | | | |
| ២៤. | | | | |
| ២៥. | | | | |

## ចុងសន្លឹក

| **ផ្នែកទទួលរងឥទ្ធិពលតាមផែនការ (សម្រាប់អ្នកទទួលបានគម្រោង ឬពួកជំនុំ)**<br>កត់ត្រាជំហានដែលផ្នែកទទួលរងឥទ្ធិពលខាងក្រោមត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញ:<br><br>• ______ប្រាជ្ញា<br>• ______ខាងសាច់ឈាម<br>• ______ខាងវិញ្ញាណ<br>• ______ខាងសង្គម | **លក្ខណៈគម្រោងគ្រាប់ពូជនៅក្នុងផែនការ**<br>កត់ត្រាជំហានដែលលក្ខណៈខាងក្រោមត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញ<br><br>• ______បណ្ដាលចិត្តដោយសារគោលបំណងរបស់ ______ព្រះជាម្ចាស់<br>• ______គ្របបាំងនៅក្នុងការអធិស្ឋាន<br>• ______សាមញ្ញ និងមានរយៈពេលខ្លី<br>• ______រៀបចំផែនការឱ្យបានល្អ<br>• ______ធនធាននៅក្នុងមូលដ្ឋាន<br>• ______មិនបោកបញ្ឆោត<br>• ______នៅខាងក្រៅពួកជំនុំ<br>• ______អ្នកដែលទទួលបានផលប្រយោជន៍ចូលរួម<br>• ______មានគោលបំណងគ្រប់ជ្រុងជ្រោយ<br>• ______ព្រះជាម្ចាស់ត្រូវបានលើកតម្កើង |
|---|---|

# ការរៀបចំផែនការគម្រោងគ្រាប់ពូជ និងការធ្វើរបាយការណ៍

## មេរៀន

**សារៈសំខាន់របស់ការរៀបចំផែនការៈ** ព្រះយេស៊ូវបានប្រាប់ដោយប្រយោលថា វាជាការឆ្លាតវៃនៅក្នុងការរៀបចំផែនការដើម្បីសង់ផ្ទះឱ្យបានហើយ ឬដើម្បីឱ្យឈ្នះសង្គ្រាម។ "ដ្បិតក្នុងពួកអ្នករាល់គ្នា បើមានអ្នកណាចង់សង់ផ្ទះពីថ្ម តើមិនអង្គុយលៃលកមើលជាមុនទេឬអី? ដើម្បីអោយដឹងជា មានល្មមនឹងធ្វើបង្ហើយបានឬមិនបាន ក្រែងកាលណាដាក់ជើងជញ្ជាំង រួចបង្ហើយមិនបាន នោះអស់អ្នកណាដែលឃើញ ក៏នឹងសើចចំអកអោយ ដោយពាក្យថា អ្នកនេះបានចាប់ផ្តើមសង់ផ្ទះ តែបង្ហើយមិនបាន។ ឬតើមានស្តេចឯណា ដែលរៀបចេញទៅច្បាំងនឹងស្តេច១ទៀត ឥតអង្គុយពិគ្រោះមើលជាមុនសិន ដើម្បីអោយដឹងជាខ្លួននាំពល១ម៉ឺន ទៅតទល់នឹងស្តេចដែលនាំពល២ម៉ឺនមកច្បាំងបាន ឬមិនបាន" (លូកា ១៤:២៨-៣១)។

បទគម្ពីរមានឧទាហរណ៍យ៉ាងច្រើនអំពីការរៀបចំផែនការ។ សត្វស្រមោចត្រៀមខ្លួនសម្រាប់រដូវត្រជាក់ ដោយខិតខំប្រមូលស្បៀង។ កំផែងក្រុងយេរូសាឡិមត្រូវបានសង់ឡើងវិញទៅតាមផែនការយ៉ាងប្រុងប្រយ័ត្ន។ សូម្បីតែព្រះជាម្ចាស់ ក៏ព្រះអង្គមានផែនការដែរ។ "ដ្បិតព្រះយេហូវ៉ាទ្រង់មានបន្ទូលថា អញស្គាល់សេចក្តីដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្តីអាក្រក់ទេ គឺគិតឱ្យបានសេចក្តីសុខវិញ ដើម្បីដល់ចុងបំផុត ឱ្យឯងរាល់គ្នាបានសេចក្តីសង្ឃឹម" (យេរេមា ២៩:១១)។ គម្រោងគ្រាប់ពូជមានលក្ខណៈសាមញ្ញ ហើយតូច ប៉ុន្តែដើម្បីឱ្យគម្រោងជោគជ័យ នោះក៏ត្រូវឱ្យមានការរៀបចំផែនការផងដែរ។ "រៀបចំផែនការដោយល្អិតល្អន់" គឺជាលក្ខណៈមួយក្នុងចំណោមលក្ខណៈទាំងឡាយរបស់គម្រោងគ្រាប់ពូជ។ ពួកជំនុំដែលរៀបចំផែនការគម្រោងគ្រាប់ពូជដោយល្អិតល្អន់ បង្កើនសក្តានុពលរបស់ពួកគេដើម្បីធ្វើគម្រោងនោះឱ្យបានល្អ លើកតម្កើងព្រះអម្ចាស់ ហើយរីកចម្រើនឡើងនៅក្នុងលទ្ធភាព និងព្រះគុណដើម្បីបម្រើ។

ពួកជំនុំមូលដ្ឋានមួយចំនួនត្រូវជឿជាក់អំពីផលប្រយោជន៍របស់ការរៀបចំផែនការ។ ពួកជំនុំខ្លះភ័យខ្លាចថា ការរៀបចំផែនការធ្វើឱ្យបាត់ការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ។ ពួកជំនុំខ្លះទៀតក៏រៀបចំផែនការ ប៉ុន្តែមិនដឹងថា ត្រូវចាប់ផ្តើមយ៉ាងដូចម្តេច។ សម្រាប់មនុស្សជាច្រើន ការរៀបចំផែនការមិនធ្លាប់មាននៅក្នុងវប្បធម៌របស់ពួកគេទេ។ អ្នកខ្លះត្រូវការឱ្យរំលឹកថា ការរៀបចំផែនការគ្រាន់តែជាទីចាប់ផ្តើមប៉ុណ្ណោះ ហើយថា គោលដៅចុងក្រោយគឺជាការបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់។ ដោយព្រោះការរៀបចំផែនការមានការលំបាកសម្រាប់ពួកជំនុំជាច្រើន យើងបានបង្កើតមគ្គុទេសក៍សម្រាប់ការរៀបចំផែនការគម្រោងគ្រាប់ពូជ។ មគ្គុទេសក៍ត្រូវបានប្រើអស់រយៈពេលជាងម្ភៃឆ្នាំមកហើយ នៅក្នុងបរិបទវប្បធម៌ផ្សេងៗជាច្រើន។ ពួកជំនុំជាច្រើនបានថ្លែងអំណរគុណ ដោយព្រោះមគ្គុទេសក៍នេះជួយ

ពួកគេឱ្យផ្តោតលើអ្វីដែលព្រះជាម្ចាស់ផ្តោតព្រះទ័យលើ។ ពួកគេក៏បានថ្លៃអំណរគុណដែលឧបករណ៍នេះមានទម្រង់ជាជាជំហាន១។ ឧបករណ៍នេះជួយពួកគេឱ្យគិតលម្អិត បែងចែកការងារ និងពិនិត្យមើលការទទួលខុសត្រូវ និងការរីកចម្រើនបានឆាប់រហ័ស។ ផលប្រយោជន៍ដ៏នឹកស្មានមិនដល់ដទៃទៀតរបស់ការរៀបចំផែនការ ត្រូវបានគ្រូគង្វាលជនជាតិអាហ្វ្រិកម្នាក់ប្រាប់ដូចតទៅនេះ:

> ការរៀបចំផែនការមិនមែនជាវប្បធម៌របស់អាហ្វ្រិកទេ។ តាមវប្បធម៌ យើងធ្វើកិច្ចការតាមជាក់ស្តែង ប៉ុន្តែការរៀបចំផែនការត្រលប់ជាមានតម្លៃយ៉ាងខ្លាំងសម្រាប់អ្នកដឹកនាំក្រុមកោសិការបស់យើង។ ពួកគេបានមើលឃើញថា គម្រោងគ្រាប់ពូជដែលត្រូវបានរៀបចំផែនការល្អិតល្អន់ មានផលផ្លែយ៉ាងធំសម្បើម និងមានឥទ្ធិពលយ៉ាងធំធេងទៅលើសហគមន៍។ ការរៀបចំផែនការត្រលប់ជាពាក់ព័ន្ធយ៉ាងខ្លាំងជាមួយយើង។ ការរៀបចំផែនការមិនត្រឹមតែជួយយើងឱ្យបង្កើតបានផលផ្លែតាមរយៈគម្រោងគ្រាប់ពូជប៉ុណ្ណោះទេ ថែមទាំងជួយអ្នកដឹកនាំរៀបចំផែនការជីវិតរបស់ពួកគេទៀតផង។ អ្នកដឹកនាំបានមើលឃើញថា ការរៀបចំផែនការសំខាន់ខ្លាំងណាស់សម្រាប់ព័ន្ធកិច្ច និងជីវិតដែលមានផលផ្លែ[១]។

**ជំហាននៅក្នុងការរៀបចំផែនការគម្រោងគ្រាប់ពូជ ការអនុវត្តន៍ ការធ្វើរបាយការណ៍ និងការវាយតម្លៃ:** គម្រោងគ្រាប់ពូជធ្វើបានយ៉ាងល្អដោយក្រុមតូច។ តាមពិតទៅ ក្រុមតូចនៃអ្នកជឿអាចរៀបចំផែនការ និងអនុវត្តបានគម្រោងដែលឆ្លុះបញ្ចាំងឱ្យឃើញសេចក្តីស្រលាញ់ និងព្រះហឫទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ ចំពោះមនុស្សនៅក្នុងសហគមន៍។ ទាំងនេះគឺជាជំហានដែលត្រូវបានផ្តល់ជូន ដើម្បីជួយសមាជិកនៅក្នុងក្រុមតូចរបស់លោកអ្នកឱ្យរៀបចំផែនការ និងអនុវត្តគម្រោងគ្រាប់ពូជ:

១. **អធិស្ឋានសូមការដឹកនាំ:** អធិស្ឋានទាំងអស់គ្នាសូមការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ។

២. **ជ្រើសរើសសេចក្តីត្រូវការ:** ជ្រើសរើសផ្នែកនៃសេចក្តីត្រូវការដែលលោកអ្នកគិតថា ឆ្លុះបញ្ចាំងអំពីផ្នែកដែលព្រះជាម្ចាស់ចង់ឱ្យលោកអ្នកធ្វើគម្រោងគ្រាប់ពូជ។

៣. **រៀបចំផែនការគម្រោងរបស់លោកអ្នក:** រួមគ្នាបំពេញមគ្គុទេសក៍សម្រាប់ការរៀបចំផែនការគម្រោងគ្រាប់ពូជ។ ចូរបន្តអធិស្ឋាននៅក្នុងចិត្តនៅក្នុងអំឡុងពេលនៃការរៀបចំផែនការទាំងមូល និងការអនុវត្តន៍គម្រោងគ្រាប់ពូជ។

- ពណ៌នាអំពីបញ្ហា ឬសេចក្តីត្រូវការ
- សង្ខេបគោលបំណងរបស់ព្រះជាម្ចាស់ពាក់ព័ន្ធនឹងបញ្ហានោះ ឬសេចក្តីត្រូវការ (ដោយមានបទគម្ពីរ)

---

[1] លោកគ្រូគង្វាល ហ្វ្រង់កូ អូណាហ្កា ផ្ញើសារអេឡិចត្រូនិចមក បប់ ម៉ូហ្វិត (ទីក្រុងកាំប៉ាឡា ប្រទេសអ៊ូហ្កាន់ដា ឆ្នាំ ២០០៥) ដែលត្រូវបានលើកឡើងនៅក្នុង *ប្រសិនបើព្រះយេស៊ូវគឺជាចៅហ្វាយក្រុង* ទំព័រ ៣០១។

- ពណ៌នាអំពីសកម្មភាពព័ន្ធកិច្ច / គម្រោង (នៅក្នុងសណ្ឋានជាចំណងជើងគម្រោង) ដែលក្រុមរបស់លោកអ្នកអាចធ្វើបាន ដោយប្រើធនធាននៅក្នុងមូលដ្ឋាន ដែលបង្ហាញចេញអ្វីដែលលោកអ្នកជឿថា តំណាងឱ្យគោលបំណងរបស់ព្រះជាម្ចាស់។
- ប្រាប់អំពីសេចក្តីត្រូវការដែលនឹងត្រូវបានបំពេញតាមរយៈគម្រោង ទាំងចម្បង និងបន្ទាប់បន្សំ។
- កត់ត្រាជំហាននៅក្នុងគម្រោង។
- សម្រាប់ជំហាននិមួយៗ សូមកត់ត្រាមនុស្សដែលលោកអ្នកត្រូវពិគ្រោះយោបល់ជាមួយ ធនធានដែលត្រូវការ អ្នកទទួលខុសត្រូវសម្រាប់ជំហាននោះ និងកាលបរិច្ឆេទបញ្ចប់សម្រាប់ជំហាននិមួយៗ។
- ពិនិត្យមើលផែនការ ដើម្បីឱ្យមើលឃើញកន្លែងដែលលក្ខណៈនិមួយៗរបស់គម្រោងគ្រាប់ពូជត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញ ឬមានហេតុផលល្អដើម្បីមិនដាក់បញ្ចូលលក្ខណៈនោះ។

៤. **បង្ហាញផែនការៈ** ជួបជាមួយអ្នកដទៃទៀតដើម្បីពិនិត្យមើលឡើងវិញ ដើម្បីទទួលបានយោបល់ ការកែលំអរ និងការលើកទឹកចិត្ត។

៥. **អនុវត្តៈ** រួមគ្នាអនុវត្តផែនការគម្រោងគ្រាប់ពូជ។

៦. **របាយការណ៍ៈ** របាយការណ៍ជាមូលដ្ឋានគ្រឹះផ្តល់ទិន្នន័យអំពីក្រុម ទិន្នន័យអំពីគម្រោង និងព័ត៌មានសំខាន់ៗ។ របាយការណ៍អាចធ្វើឡើងជាទម្រង់របាយការណ៍ ឬទម្រង់ពណ៌នា។ ដើម្បីធ្វើតាមទម្រង់របាយការណ៍ សូមសរសេរទាំងបីផ្នែកនៅលើក្រដាស និងផ្តល់ព័ត៌មានដូចតទៅនេះ:

- ទិន្នន័យអំពីក្រុមៈ តើក្រុម ឬពួកជំនុំមានឈ្មោះអ្វី? ស្ថិតនៅកន្លែងណា? តើនរណាជាអ្នកដែលត្រូវទាក់ទងសម្រាប់គម្រោង?
- ទិន្នន័យអំពីគម្រោងៈ តើគម្រោងមានឈ្មោះ ឬចំណងជើងអ្វី? តើទីក្រុង ឬតំបន់ដែលត្រូវបម្រើឈ្មោះអ្វី? តើបទគម្ពីរអ្វីដែលបានប្រាប់លោកអ្នកអំពីគោលបំណងរបស់ព្រះជាម្ចាស់? តើគម្រោងមានកាលបរិច្ឆេទយ៉ាងដូចម្តេច? តើផ្នែកចម្បងដែលទទួលរងឥទ្ធិពលមានអ្វីខ្លះ និងផ្នែកបន្ទាប់បន្សំដែលទទួលរងឥទ្ធិពលមានអ្វីខ្លះ?
- ព័ត៌មានសំខាន់ៗៈ តើបានធ្វើអ្វីនៅក្នុងគម្រោងនេះ? តើគម្រោងនេះជាគំនិតរបស់អ្នកណា? តើបានចំណាយរយៈពេលប៉ុន្មានថ្ងៃដើម្បីរៀបចំគម្រោងនេះ? តើបានប្រើរយៈពេលប៉ុន្មានដើម្បីធ្វើគម្រោងនេះ? តើនរណាខ្លះបានចូលរួមនៅក្នុងការធ្វើគម្រោងនេះ? តើនរណាគឺជាអ្នកទទួលបានផលប្រយោជន៍ចម្បងពីគម្រោងនេះ? តើអ្នកដែលទទួលបានផលប្រយោជន៍បានចូលរួមយ៉ាងដូចម្តេច? តើបានត្រូវការធនធានអ្វីខ្លះ? តើលោកអ្នកបានធនធានទាំងនោះមកពីណា? តើអ្នកដែលកំពុងត្រូវបានជួយបានរួមចំណែកជួយធនធានអ្វីខ្លះ? តើមានសញ្ញាណអ្វីដែលបង្ហាញថា ព្រះជាម្ចាស់បានប្រទានពរដល់គម្រោងនេះ?

របាយការណ៍ក៏អាចធ្វើតាមទម្រង់ពណ៌នា ឬរឿង។ នេះគឺជាឧទាហរណ៍ជាក់ស្ដែងមួយ។ ពួកជំនុំវណ្ណៈកណ្ដាលមួយបានបម្រើអ្នកជិតខាងខ្លួននៅក្នុងតំបន់ក្រីក្រដែលនៅជិតនោះអស់រយៈពេលជាច្រើនឆ្នាំ ដោយបានជួបប្រទះសេចក្ដីត្រូវការគ្រប់បែបយ៉ាង។ ស្ថានភាពដ៏អាក្រក់របស់បង្គន់តូចៗក្រៅផ្ទះបានធ្វើឱ្យពួកគេដឹងអំពីស្ថានភាពរស់នៅរបស់អ្នកនៅក្នុងតំបន់ក្រីក្រនោះ។ សមាជិកពួកជំនុំបានឆ្ងល់ថា "តើជីវិតរស់នៅរបស់ពួកគេនឹងមានលក្ខណៈយ៉ាងដូចម្ដេច នៅរដូវត្រជាក់? តើពួកគេនឹងនៅតែមានសុខភាពល្អយ៉ាងដូចម្ដេច ជាពិសេសក្មេងៗ?"។ ហេព្រើរ ១៣:៣ បានលើកទឹកចិត្តពួកគេថា "ចូរនឹកចាំពីពួកអ្នកជាប់គុក ទុកដូចជាជាប់ចំណងជាមួយគ្នា ហើយពីពួកអ្នកដែលត្រូវគេធ្វើបាបផង"។ ពួកគេបានលះបង់ធនធាន និងពេលវេលារបស់ពួកគេ ដើម្បីកសាងបង្គន់ទាំងនោះឡើងវិញ។ កម្មករសំណង់បានឱ្យពេលវេលាមួយថ្ងៃ។ អ្នកលក់បានចុះតម្លៃសម្រាប់សំភារៈ។ អ្នកនៅក្នុងសហគមន៍បានជួយដោយត្រេកអរ។ អ្នកដែលទទួលបានផលប្រយោជន៍មានមនុស្សពេញវ័យប្រហែលដប់ប្រាំនាក់ និងកុមារប្រាំមួយនាក់។ ផលប្រយោជន៍មួយផ្សេងទៀតគឺថា សមាជិកពួកជំនុំបានយល់កាន់តែច្បាស់ថា ព្រះជាម្ចាស់កំពុងប្រើពួកគេដើម្បីផ្សះផ្សាអ្នកជិតខាងរបស់ពួកគេជាមួយបរិដ្ឋាន ដែលជាមួយផ្នែកនៃរបៀបវារៈធំរបស់ព្រះជាម្ចាស់។ តាមរយៈកិច្ចការទាំងអស់នេះ ព្រះជាម្ចាស់ត្រូវបានលើកតម្កើង[២]។

៧. **ការវាយតម្លៃគម្រោងគ្រាប់ពូជៈ** នេះគឺជាយោបល់ជាច្រើនដើម្បីជួយពួកជំនុំ ឬក្រុមតូចវាយតម្លៃគម្រោងគ្រាប់ពូជដែលទើបតែបានបញ្ចប់។

- តើគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់សហគមន៍ត្រូវបានពង្រីកតទៅទៀតតាមវិធីអ្វីខ្លះ? តើព្រះជាម្ចាស់បានធ្វើការយ៉ាងដូចម្ដេចនៅក្នុងជីវិតរបស់អ្នកចូលរួម? តើព្រះជាម្ចាស់បានធ្វើការយ៉ាងដូចម្ដេចនៅក្នុងសហគមន៍?
- តើលោកអ្នករៀនបានមេរៀនអ្វី តាមរយៈដំណើរការរៀបចំផែនការ និងការអនុវត្តន៍គម្រោងគ្រាប់ពូជ? តើលោកអ្នករៀនបានអ្វីអំពីព្រះជាម្ចាស់? អំពីខ្លួនឯង? អំពីសហគមន៍? អំពីនគរព្រះ?
- តើជំហានថែបំប៉នអ្វីខ្លះដែលចាំបាច់ ក្រោយពីបញ្ចប់គម្រោងគ្រាប់ពូជ? តើផ្នែកមួយចំនួនដែលអ្នកចូលរួមត្រូវការការបណ្ដុះបណ្ដាលថែមទៀតមានអ្វីខ្លះ? តើលោកអ្នកគិតថា ព្រះជាម្ចាស់ចង់ឱ្យលោកអ្នកធ្វើអ្វីបន្ទាប់ទៀត?

---

[2] Cleiton and Eleuza Oliveira, ដែលត្រូវបានលើកឡើងនៅក្នុងសៀវភៅ *ប្រសិនបើព្រះយេស៊ូវគឺជាចៅហ្វាយក្រុង* ទំព័រទី ៣០០។

"វាយតម្លៃតាមបទដ្ឋាននគរព្រះ" គឺជាលក្ខណៈមួយផ្សេងទៀតនៅក្នុងចំណោមលក្ខណៈរបស់គម្រោងគ្រាប់ពូជ។ លក្ខណៈនេះសំខាន់ខ្លាំងណាស់ ប្រសិនបើគម្រោងគ្រាប់ពូជរបស់យើងលើសពីការខិតខំប្រឹងប្រែងរបស់មនុស្សដែលមានបំណងល្អ។ នេះគឺជាសំណួរ"បទដ្ឋាននគរព្រះ"មួយចំនួន ដើម្បីពិនិត្យមើលគម្រោងគ្រាប់ពូជក្រោយពេលបញ្ចប់:

- ✓ តើព្រះជាម្ចាស់ត្រូវបានមើលឃើញជាអ្នកចាប់ផ្តើមសកម្មភាពបម្រើនេះដែរឬទេ?
- ✓ តើព្រះជាម្ចាស់បានទទួលព្រះកិត្តិយស និងការលើកតម្កើងពីអ្នកមើលដែរឬទេ? តើព្រះអង្គបានទទួលកិត្តិយសជាងអ្នកដែលបានធ្វើគម្រោងដែរឬទេ?
- ✓ តើព្រះជាម្ចាស់បានធ្វើឱ្យធនធានចម្រើនច្រើនឡើងដែរឬទេ? តើគណិតវិទ្យានគរព្រះបានកើតឡើងដែរឬទេ?
- ✓ តើមនុស្សបានទទួលព្រះពរ ឬបានទទួលរងឥទ្ធិពលវិជ្ជមានពីគម្រោងនេះដែរឬទេ?
- ✓ តើសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់មើលឃើញច្បាស់ដែរឬទេ? តើគោលបំណងរបស់ព្រះអង្គត្រូវបានបង្ហាញចេញដែរឬទេ?

តើការវាយតម្លៃមានគោលបំណងអ្វី? ទីមួយដើម្បីមើលឃើញរបៀបធ្វើដំណើរឆ្ពោះទៅមុខ និងបន្តបម្រើតទៅទៀត។ ទីពីរ ដើម្បីជួយឱ្យយើងមើលឃើញថាតើយើងកំពុងត្រូវបានព្រះជាម្ចាស់ដឹកនាំដែរឬអត់នៅក្នុងការបម្រើរបស់យើង។ ទីបី គឺដើម្បីប្តូររបត់របស់យើង ប្រសិនបើចាំបាច់។ លើសពីនេះទៅទៀត ការវាយតម្លៃគឺដើម្បីវាស់ភាពស្មោះត្រង់ និងការស្តាប់បង្គាប់របស់យើង។ យើងប្រហែលជាមើលឃើញ ឬប្រហែលជាមិនបានមើលឃើញលទ្ធផលធំធេងចេញពីការបម្រើដោយស្មោះត្រង់ និងដោយសេចក្តីស្រលាញ់របស់យើងទេ។ ប៉ុន្តែព្រះជាម្ចាស់លើកតម្កើងអ្នកដែលខ្ជាប់ខ្ជួនទាំងនោះ។ ព្រះអង្គនាំលទ្ធផលមកតាមពេលវេលារបស់ព្រះអង្គ មិនមែនពេលវេលារបស់យើងទេ។ ដូចជាអស់អ្នកដែលជាវីរបុរសនៃសេចក្តីជំនឿដែលត្រូវបានលើកឡើងនៅក្នុងហេព្រើរ ១១ ដែរ យើងត្រូវបានត្រាស់ហៅឱ្យស្មោះត្រង់ ទោះបីយើងមើលឃើញ ឬមិនមើលឃើញលទ្ធផលក៏ដោយ។

មានវិធីសាស្ត្រផ្សេងៗជាច្រើនសម្រាប់ធ្វើរបាយការណ៍ និងការវាយតម្លៃ[3]។ ចូរជ្រើសរើសយកទម្រង់នៃរបាយការណ៍ដែលល្អសម្រាប់ក្រុមរបស់លោកអ្នក ហើយធ្វើរបាយការណ៍នោះជាមួយគ្នា។ សូមចែកចាយរបាយការណ៍នោះជាមួយពួកជំនុំ ប្រសិនបើស័ក្តិសម។ ចូរអធិស្ឋាន វាយតម្លៃ និងរៀបចំផែនការសម្រាប់របៀបបន្តបង្ហាញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដែលអាចមើលឃើញនឹងភ្នែក។

---

[3] សូមមើលជំពូក ១៣ និង ១៤ នៅក្នុងសៀវភៅ *ប្រសិនបើព្រះយេស៊ូវគឺជាចៅហ្វាយក្រុង* សម្រាប់ជម្រើសបន្ថែមទៀតអំពីការធ្វើរបាយការណ៍ និងការវាយតម្លៃ។

សូមចែកចាយរបាយការណ៍អំពីគម្រោងរបស់លោកអ្នកជាមួយគ្រឹះស្ថាន Harvest តាមគេហទំព័រដូចតទៅនេះ www.harvestfoundaiton.org ។ សូមផ្ញើរូបភាពសកម្មភាពគម្រោងរបស់លោកអ្នក។ យើងចង់ចែកចាយបទពិសោធន៍របស់លោកអ្នកជាមួយពួកជំនុំផ្សេងៗនៅជុំវិញពិភពលោក។

សំណួរចុងក្រោយគឺថាៈ តើគេអាចនិយាយបែបនេះអំពីការបម្រើរបស់លោកអ្នកបានដែរឬទេ? "ពីព្រោះការជួយពួកបរិសុទ្ធនេះមិនមែនគ្រាន់តែបំពេញសេចក្តីដែលគេត្រូវការប៉ុណ្ណោះ គឺបានចំរើនឡើងជាហូរហៀរដល់ព្រះដែរ ដោយសារពាក្យគេអរព្រះគុណជាច្រើន ហើយដោយគេឃើញភស្តុតាងពីការជំនួយនេះ នោះគេសរសើរដំកើងដល់ព្រះ ដោយព្រោះអ្នករាល់គ្នាសំដែងច្បាស់ថា ខ្លួនជាអ្នកចុះចូលតាមដំណឹងល្អនៃព្រះគ្រីស្ទពិត ហើយដោយព្រោះការសទ្ធាដែលអ្នករាល់គ្នាផ្ញើទៅគេ និងមនុស្សទាំងអស់ផង" (២ កូរិនថូស ៩:១២-១៣)។

សូមចងចាំថា ការបង្ហាញចេញពីរបៀបវារៈធំរបស់ព្រះជាម្ចាស់ និងសេចក្តីស្រលាញ់របស់ទ្រង់គួរតែជាមួយផ្នែកនៅក្នុងរបៀបរស់នៅតទៅរបស់យើង ឬជារបៀបធ្វើព័ន្ធកិច្ចសម្រាប់ពួកជំនុំមូលដ្ឋានទាំងអស់។

*By Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*

*Copyright 2007 by the Disciple Nations Alliance*

*701 N. 1st Street Phoenix, AZ 85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*

*ការអនុញ្ញាតៈ លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាមទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ និងកុំថតចម្លងច្រើនជាង ១០០០ ច្បាប់។*

## ធនធានល្អដែលបានផ្តល់ជាយោបល់ជូនៈ

Moffitt, Bob, *If Jesus Were Mayor*. Monarch Books, 2006, chapters 12 and 13.

Disciple Nations Alliance website: www.disciplenations.org/resources/course. Section: Wholistic Ministry